សាលាព្រះគម្ពីរភ្នំពេញ

លេខ២ ខែកក្កដា ២០១៥

# ព្រឹត្តិបត្រ វាលស្រែស្រូវទុំ

www.ppbs.edu.kh

ប្រសាសន៍របស់សាស្ត្រាចារ្យ សាំង សុខហ៊ាង :

## ចូររត់បែបឲ្យបានរង្វាន់ចុះ

ដោយសារព្រះគុណរបស់ព្រះ ទ្រង់បានឲ្យខ្ញុំចាប់កំណើតមកក្នុងលោកិយនេះ ជាជនជាតិខ្មែរម្នាក់ ដែលទ្រង់បានទុកឲ្យមានជីវិតរស់នៅក្រោមរបបប្រល័យពូជសាសន៍ ទោះបីជាជិតនឹងស្លាប់ក៏ដោយ ព្រោះទ្រង់បានជ្រើសរើសខ្ញុំជាកូនរបស់ទ្រង់ ដោយឲ្យខ្ញុំបានទទួលជឿទ្រង់ជាព្រះអម្ចាស់ និងជាព្រះសង្គ្រោះផ្ទាល់ខ្លួននៅឆ្នាំ១៩៨១។ នេះគឺជាការចាប់ផ្តើមរត់ប្រណាំងនៅក្នុងជីវិតរបស់ខ្ញុំ ក្នុងការដើរតាមទ្រង់ និងរស់នៅសម្រាប់ទ្រង់។ ពេលដែលខ្ញុំកំពុងបម្រើការងារជាបុគ្គលិកពេទ្យឆ្មបម្នាក់ ខ្ញុំមានបំណងចង់ផ្សាយប្រាប់គេពីជំនឿរបស់ខ្ញុំថា ខ្ញុំបានស្គាល់ព្រះពិតដែលអាចជួយសង្គ្រោះមនុស្សឲ្យរួចពីបាបបាន គឺព្រះយេស៊ូវគ្រីស្ទ ប៉ុន្តែគ្មាននរណាម្នាក់ជឿខ្ញុំទេ។ ខ្ញុំបានអធិស្ឋានទូលសួរទ្រង់ថា "ព្រះអម្ចាស់យេស៊ូវអើយ ខ្ញុំមានបំណងចង់នាំប្រជាជនខ្ញុំឲ្យទទួលជឿទ្រង់ដូចខ្ញុំដែរ តើឲ្យខ្ញុំធ្វើដូចម្តេច?"

អរព្រះគុណព្រះ នៅឆ្នាំ១៩៩២ សាលាព្រះគម្ពីរភ្នំពេញបានចាប់ផ្តើមបើកវគ្គហ្វឹកហ្វឺនផ្នែកព័ន្ធកិច្ចគ្រីស្ទាន ខ្ញុំក៏សម្រេចចិត្តដាក់ពាក្យចូលរៀន ហើយក៏ប្តេជ្ញាថា នឹងធ្វើការបម្រើព្រះពេញពេលវិញ។ ខ្ញុំបានបញ្ចប់ដោយជោគជ័យ និងបានទទួលសញ្ញាបត្រឱប្លូមព័ន្ធកិច្ចគ្រីស្ទាននៅឆ្នាំ១៩៩៥ ហើយត្រូវបានសាលាជ្រើសរើសឲ្យធ្វើជាបុគ្គលិក ផ្នែកការិយាល័យសិក្សា និងជាគិលានុបដ្ឋាយិកា។ ដោយសារសេចក្តីត្រូវការរបស់សាលាក្នុងការអភិវឌ្ឍន៍គ្រូក្នុងស្រុក សាលាបានបញ្ជូនខ្ញុំទៅរៀនបន្ថែមនៅ Singapore Bible College ប្រទេសសិង្ហបុរីនៅឆ្នាំ២០០៣ ហើយបានទទួលបរិញ្ញាបត្រផ្នែកទេវសាស្ត្រនៅឆ្នាំ២០០៧ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសិក្សាធិការគ្រីស្ទាននៅឆ្នាំ២០១០ ខ្ញុំក៏បានក្លាយទៅជាសាស្ត្រាចារ្យពេញពេលចាប់ពីពេលនោះមក។ ការដែលទទួលបានទាំងអស់នេះ គឺមិនមែនដោយសារចំណេះដឹង ឬកម្លាំងប្រាជ្ញារបស់ខ្លួនខ្ញុំទេ គឺដោយសារព្រះគុណព្រះតែ១គត់។

ខ្ញុំពេញចិត្តក្នុងការងារជាគ្រូបង្រៀនព្រះគម្ពីរនេះ។ ក្រៅពីការបង្រៀន ខ្ញុំបានជួយការងារខាងផ្នែកការិយាល័យសិក្សា និងផ្នែកព័ន្ធកិច្ចកម្មសិក្សាផងដែរ ខ្ញុំទទួលបានបទពិសោធន៍ជាច្រើនចេញពីការងារទាំងនោះ។ ប៉ុន្តែនៅខែវិច្ឆិកា ឆ្នាំ២០១៤ ខ្ញុំមានបញ្ហាសុខភាពយ៉ាងធ្ងន់ធ្ងរ ជិតនឹងស្លាប់ ដោយសារប្រអប់បិទបើកសំលេងនៅដើមបំពង់ករបស់ខ្ញុំបានខូច មិនអាចធ្វើចលនាបាន បណ្តាលឲ្យស្ទះផ្លូវដកដង្ហើម ធ្វើឲ្យខ្ញុំមិនអាចដកដង្ហើមចូលបាន ដូច្នេះគ្រូពេទ្យបានវះកាត់ចោះបំពង់ខ្យល់ ហើយដាក់បំពង់ធ្វើជាផ្លូវដង្ហើមថ្មីសម្រាប់ខ្ញុំ។ អរព្រះគុណព្រះអង្គ ខ្ញុំនៅតែអាចនិយាយបានក៏ប៉ុន្តែមិនអាចបង្រៀនបានទេ។ ទោះបីមានការលំបាកខ្លះៗ ក្នុងការរស់នៅជាមួយនឹងឧបករណ៍ជំនួយខាងផ្លូវដង្ហើមថ្មីនេះក៏ដោយ តែខ្ញុំនៅតែអរព្រះគុណព្រះយ៉ាងខ្លាំង ដែលទ្រង់បានទុកឲ្យខ្ញុំនៅមានជីវិតរស់នៅ ដើម្បីបំពេញការងារបម្រើទ្រង់នៅក្នុងសាលាព្រះគម្ពីរភ្នំពេញបន្តទៅទៀត គឺដោយសារព្រះគុណព្រះ ដែលខ្ញុំអាចនៅមានជីវិតរស់នៅ ដើម្បីបញ្ចប់ផែនការរបស់ទ្រង់។

ពេលខ្ញុំសម្លឹងមើលពីជីវិតនៃការរត់ប្រណាំងរបស់ខ្ញុំ ធ្វើឲ្យខ្ញុំមើលឃើញព្រះគុណ និងសេចក្តីស្រឡាញ់របស់ព្រះដ៏អស្ចារ្យមិនអាចពិពណ៌នាបាន ហើយខ្ញុំបានដឹងយ៉ាងច្បាស់ថា អ្វីៗដំណើរការបានល្អនៅក្នុងជីវិតនេះ គឺជាការរៀបចំជាមុនរបស់ទ្រង់(អេភេសូរ ២:១០) ហើយមិនមែនខ្ញុំទេដែលអាចធ្វើការទាំងអស់នោះបាន គឺជាព្រះគ្រីស្ទទ្រង់ជាអ្នកចម្រើនកម្លាំងដល់ខ្ញុំ(ភីលីព៤:១៣)។ ខ្ញុំរស់នៅមិនមែនខ្លួនខ្ញុំទៀតទេ គឺព្រះគ្រីស្ទទ្រង់រស់ក្នុងខ្ញុំ ហើយខ្ញុំសង្ឃឹមថា ខ្ញុំនឹងបញ្ចប់បានល្អ នូវការរត់ប្រណាំងបែបឲ្យបានរង្វាន់ គឺជាមកុដមួយដែលមិនចេះពុករលួយឡើយ(១កូរិនថូស៩:២៥ខ) ដោយពឹងអាងនៅក្រោមព្រះគុណ និងព្រះរាជកិច្ចដឹកនាំរបស់ព្រះនៃសេចក្តីស្រឡាញ់ ជាព្រះដែលមានព្រះជន្មរស់នៅសព្វថ្ងៃ គឺព្រះនាមព្រះយេស៊ូវគ្រីស្ទ។

អាម៉ែន!






# អបអរសាទរ! និស្សិតសាលាព្រះគម្ពីរភ្នំពេញដែលទទួលសញ្ញាបត្រឆ្នាំ២០១៥



## កែម សុម៉ាលី

***តើអ្នកបានលូតលាស់ខាងព្រលឹងវិញ្ញាណយ៉ាងណាក្នុងរយៈពេល4ឆ្នាំមកនេះ?***

ខ្ញុំសូមអរព្រះគុណដល់ព្រះ ដែលបានប្រទានឲ្យខ្ញុំមករៀននៅទីនេះ ខ្ញុំជឿព្រះជាង១០ឆ្នាំហើយ មុនពេលខ្ញុំរៀននៅទីនេះ ជំនឿរបស់ខ្ញុំដូចជាជំនឿរបស់កូនក្មេងនៅឡើយ។ ខ្ញុំដឹងរឿងជាច្រើនក្នុងគម្ពីរ តែមិនមានជំនឿខ្លាំងទេ។ តែតាមរយៈការរៀននៅទីនេះ ជំនឿខ្ញុំបានលូតលាស់ជាងមុន ស្គាល់ច្បាស់ពីព្រះដែលខ្ញុំបានជឿតាម ស្រឡាញ់ព្រះច្រើនជាងមុន ក៏មានចិត្តឆេះឆួលក្នុងការបម្រើទ្រង់។ ពីមុន ខ្ញុំខ្លាចការផ្សាយដំណឹងល្អណាស់ ក៏មិនខ្វល់ថា នរណាបានសង្គ្រោះឬអត់ឡើយ។ តែឥឡូវនេះ ខ្ញុំមានបំណងចង់ឲ្យមនុស្សបានជឿព្រះទាំងអស់គ្នា។ ខ្ញុំយល់ដឹងបានច្រើនអំពីទេវសាស្ត្រ និងគោលលទ្ធិដែលត្រឹមត្រូវ។ ខ្ញុំរំពឹងថា ព្រះជាម្ចាស់នៅតែបង្រៀនខ្ញុំរហូត។



## គី រ៉ាវី

***តើអ្នកបានលូតលាស់ខាងព្រលឹងវិញ្ញាណយ៉ាងណាក្នុងរយៈពេល4ឆ្នាំមកនេះ?***

ព្រះបានផ្លាស់ប្រែជីវិតខ្ញុំជាច្រើន ទ្រង់បង្រៀនខ្ញុំឲ្យចេះអត់ធ្មត់ ទោះជាមានបញ្ហាអ្វីក៏ដោយ។ ជាមួយគ្នា ព្រះអង្គបានដកសេចក្តីអំណួតចេញពីជីវិតខ្ញុំ តែផ្តល់ឲ្យខ្ញុំនូវសេចក្តីស្រឡាញ់ពោរពេញ ហើយបង្រៀនខ្ញុំឲ្យចេះចែករំលែកសេចក្តីស្រឡាញ់ដល់មនុស្ស ដែលនៅជុំវិញខ្លួនខ្ញុំ ព្រមទាំងឲ្យខ្ញុំចេះរាប់រកខ្មាំងសត្រូវរបស់ខ្ញុំផងដែរ។

***តើព្រះបានដឹកនាំអ្នកក្នុងការបម្រើទ្រង់យ៉ាងណា? ហើយអ្វីជាគម្រោងផែនការបន្ទាប់ពីបញ្ចប់ការរៀននៅសាលាព្រះគម្ពីរនេះទៅ?***

ព្រះអង្គបានដឹកនាំខ្ញុំឲ្យបម្រើទ្រង់ ប្រកបដោយភាពតស៊ូ ព្រមទាំងឲ្យខ្ញុំមានសេចក្តីស្មោះត្រង់ចំពោះពួកជំនុំ ជាពិសេសចំពោះទ្រង់។ គម្រោងក្រោយចប់ពីសាលាគម្ពីរនេះទៅ គឺខ្ញុំចង់ធ្វើជាគ្រូគង្វាល។ ជាមួយគ្នា ខ្ញុំចង់ជួយបង្រៀនព្រះបន្ទូលដល់កុមារកំព្រានៅតាមផ្លូវ ដោយបង្ហាញសេចក្តីស្រឡាញ់របស់ព្រះដល់ពួកគេ ដើម្បីឲ្យពួកគេមើលឃើញសេចក្តីស្រឡាញ់របស់ទ្រង់។



## ហៃ សុភឿន

***តើអ្នកបានលូតលាស់ខាងព្រលឹងវិញ្ញាណយ៉ាងណាក្នុងរយៈពេល4ឆ្នាំមកនេះ?***

ខ្ញុំលូតលាស់ខាងវិញ្ញាណជាច្រើន ពីព្រោះសាស្ត្រាចារ្យនៅទីនេះបានបង្រៀនខ្ញុំឲ្យបានស្គាល់ព្រះ និងព្រះហឫទ័យទ្រង់បានច្រើនណាស់ ពួកគាត់បានយកចិត្តទុកដាក់ថែរក្សាព្រលឹងវិញ្ញាណរបស់ខ្ញុំ ឲ្យលូតលាស់ពី១ឆ្នាំទៅ១ឆ្នាំ។ ហើយព្រះបានបំផ្លាស់បំប្រែជីវិតខ្ញុំយ៉ាងច្រើន តាំងពីអត្តចរិតក្នុងការរស់នៅ ពាក្យសំដីក្នុងការទំនាក់ទំនង ការបន្ទាបខ្លួន ចុះចូល ព្រមទាំងមានចិត្តក្នុងការងារបម្រើព្រះ។

***តើព្រះបានដឹកនាំអ្នកក្នុងការបម្រើទ្រង់យ៉ាងណា? ហើយអ្វីជាគម្រោងផែនការបន្ទាប់ពីបញ្ចប់ការរៀននៅសាលាព្រះគម្ពីរនេះទៅ?*** ព្រះបានដឹកនាំខ្ញុំក្នុងការងារបម្រើទ្រង់ គឺព្រះបានផ្តល់ឲ្យខ្ញុំមានចិត្តអំណរក្នុងកិច្ចការបម្រើទ្រង់ ព្រមទាំងឲ្យនាងខ្ញុំមានកម្លាំងចិត្តក្នុងការបម្រើ មានចិត្តឆេះឆួលក្នុងព័ន្ធកិច្ចបម្រើព្រះ។ ហើយនាងខ្ញុំក៏មានគម្រោងថា ត្រឡប់ទៅក្រុមជំនុំដើមរបស់ខ្ញុំវិញ ដើម្បីពង្រឹងក្រុមជំនុំរបស់ខ្ញុំ ពេលក្រុមជំនុំខ្ញុំរឹងមាំហើយ ខ្ញុំនឹងទៅបង្កើតក្រុមជំនុំថ្មីដែលនៅជិតភូមិរបស់ខ្ញុំ គឺខ្ញុំធ្វើការឃោងចាប់អ្នកដទៃទៀត។



**ចាំង សារ៉ែម**

*តើអ្នកបានលូតលាស់ខាងព្រលឹងវិញ្ញាណយ៉ាងណាក្នុងរយៈពេល4ឆ្នាំមកនេះ?*

ខ្ញុំមានការរីកចម្រើនជាច្រើន ទាំងខាងវិញ្ញាណនិងសាច់ឈាម។ ព្រះបានផ្លាស់ប្រែជីវិតខ្ញុំពី១ឆ្នាំទៅ១ឆ្នាំ កាន់តែល្អប្រសើរឡើង ជីវិតខ្ញុំកាន់តែមានភាពស្និទ្ធស្នាលជាមួយព្រះ ឯការបម្រើព្រះក្នុងពួកជំនុំ គឺខ្ញុំបានរៀនជាច្រើនពីទំនាក់ទំនងជាមួយព្រះ និងមនុស្សដែលនៅក្នុង សហគមន៍របស់ខ្ញុំ បានជួយឲ្យខ្ញុំបានមើលឃើញពីបេសកកម្មដ៏ធំរបស់ព្រះដែលខ្ញុំត្រូវបំពេញថ្វាយទ្រង់។ មួយទៀត ខ្ញុំបានយល់ពីការត្រាស់ហៅ និងផែនការដែលព្រះមានសម្រាប់ខ្ញុំនៅពេលអនាគត ដែលខ្ញុំទទួលបានកំឡុងពេលសិក្សាកន្លងមក។



**សៅ ចាន់ធី**

*តើអ្នកបានលូតលាស់ខាងព្រលឹងវិញ្ញាណយ៉ាងណាក្នុងរយៈពេល4ឆ្នាំមកនេះ?*

ខ្ញុំបានលូតលាស់ជាខ្លាំង និងរឹងមាំខាងវិញ្ញាណ មានសេចក្ដីក្លាហានក្នុងការដឹកនាំ មានទំនាក់ទំនងជាមួយព្រះល្អជាងពីមុនឆ្ងាយណាស់។ ខ្ញុំស្គាល់អ្វីត្រូវ អ្វីខុស ហើយខ្ញុំអាចការពារខ្លួនពីគោលលទ្ធិខុសឆ្គងបាន។ ខ្ញុំមានអំណរនៅពេលខ្ញុំបម្រើព្រះ ធ្វើការថ្វាយព្រះ និងទំនាក់ទំនងជាមួយព្រះ។ ខ្ញុំបានលូតលាស់ ហើយក៏បានជួយឲ្យពួកជំនុំរបស់ខ្ញុំបានលូតលាស់ជាមួយខ្ញុំដែរ។

# ការដឹកនាំនៅសាលាព្រះគម្ពីរភ្នំពេញ

ដោយ មហាវិទ្យាធិការរង តាំង ណារី

គម្ពីរភីលីព ២:១៣-១៤

«ដ្បិតគឺជាព្រះហើយដែលបណ្ដាលចិត្តអ្នករាល់គ្នា ឲ្យមានទាំងចំណង់ចង់ធ្វើ ហើយឲ្យបានប្រព្រឹត្តតាមបំណងព្រះហឫទ័យទ្រង់ដែរ ចូរធ្វើគ្រប់ការទាំងអស់ដោយឥតត្អូញត្អែរ ឥតប្រកែក» ។



មហាវិទ្យាធិការស្ដីទី **ស៊ុន ឌុទ្ធី** មហាវិទ្យាធិការរងនិងប្រធានរដ្ឋបាល **តាំង ណារី**
អ្នកសម្របសម្រួលផ្នែកបណ្ណាល័យ ផ្នែកបោះពុម្ពនិងនិពន្ធ **សាំង សុខហ៊ាង** ប្រធានផ្នែកនិស្សិត **ញ៉ែម វណ្ណា**

ការបម្រើព្រះមានទាក់ទងនឹងការត្រាស់ហៅរបស់ព្រះ រួមទាំងឆន្ទៈរបស់មនុស្សដែលព្រះទ្រង់បានត្រាស់ហៅនោះ។ ឯលទ្ធផលនៃការត្រាស់ហៅ វាជាប់ទាក់ទងជាមួយនឹងការប្ដេជ្ញាចិត្តរបស់បុគ្គលម្នាក់ៗ ការព្យាយាមពុះពារជំនះឧបសគ្គ ការបន្ទាបខ្លួន និងការអនុវត្តន៍តាមដោយការស្ដាប់បង្គាប់ដល់ព្រះជាម្ចាស់។ មានមនុស្សជាច្រើនបានដើរតាមព្រះ តែមិនស្គាល់ការត្រាស់ហៅពិតប្រាកដទេ ហើយទីបំផុតក៏បរាជ័យក្នុងភាពជាអ្នកបម្រើ ។ អ្នកខ្លះមានការត្រាស់ហៅមែន តែមិនមានឆន្ទៈពិតប្រាកដក្នុងការឆ្លើយតបនឹងការត្រាស់ហៅទេ ដោយសម្លឹងមើលទៅឯលោកិយ (ទ្រព្យសម្បត្តិ និង កេរ្តិ៍ឈ្មោះ)ជាជាងការបម្រើដោយលះបង់តាមគំរូព្រះយេស៊ូវ និង ពួកសាវក។

យើងខ្ញុំមិនអួតខ្លួនថាជាអ្នកល្អ ត្រឹមត្រូវ ដើរតាមព្រះបានដោយឥតខ្ចោះនោះទេ តែយើងកំពុងតែបង្ហើយនូវសេចក្ដីសង្គ្រោះរបស់យើងដោយកោតខ្លាច ហើយញាប់ញ័រ ក្នុងភាពជាអ្នកបម្រើដែលមានការត្រាស់ហៅ។ ដោយមានព្រះដឹកនាំ, មានការណែនាំ និងការជួយជ្រោមជ្រែងអស់អំពីចិត្តពីគណៈកម្មាធិការនាយក, ការរួមចំណែកដ៏សកម្មនិងស្មោះសទាំងស្មារតី និងសម្ភារៈពីសាស្ត្រាចារ្យ និងបុគ្គលិកចម្រុះជាតិសាសន៍, ពីអ្នកដឹកនាំពួកជំនុំនៅតាមបណ្ដាវិហារទាំងក្នុងនិងក្រៅប្រទេស បានធ្វើឲ្យសាលាព្រះគម្ពីរភ្នំពេញនៅតែបោះជំហានទៅមុខយ៉ាងល្អប្រសើរ និងរឹងមាំក្នុងទិសដៅអភិវឌ្ឍន៍មនុស្សជំនាន់ថ្មីមួយដែលជាអ្នកបម្រើព្រះប្រកបដោយថាមពល ក្នុងការបំពេញមហាបេសកកម្មថ្វាយព្រះជាម្ចាស់ ដែលទ្រង់ស័ក្តិសមនឹងទទួលនូវការសរសើរតម្កើងនិងព្រះកិត្តិគុណ ពីយើងទាំងអស់គ្នាដែលជាស្នាព្រះហស្តរបស់ទ្រង់។

# ការផ្លាស់ប្តូរថ្នាក់ដឹកនាំសាលាព្រះគម្ពីរភ្នំពេញ





យើងបន្តអរព្រះគុណព្រះជាម្ចាស់ សម្រាប់ការដឹកនាំដ៏រឹងមាំ និងចិត្តកោតខ្លាចព្រះជាម្ចាស់ ដែលទ្រង់បានប្រទានដល់សាលាព្រះគម្ពីរភ្នំពេញជាច្រើនឆ្នាំមកនេះ។ យើងក៏ចង់អរព្រះគុណព្រះជាម្ចាស់ ដែលបានប្រទានឲ្យលោកគ្រូ ទេព សំណាង បានដឹកនាំជាមហាវិទ្យាធិការក្នុងពេលកន្លងមក។ ប៉ុន្តែ កាលពីខែមីនា ឆ្នាំ២០១៥ លោកគ្រូបានចាកចេញពីមុខងារនេះទៅធ្វើជានាយកប្រតិបត្តិ នៃប្រិយសម្ពន្ធគ្រីស្ទបរិស័ទកម្ពុជា។ សាលាបានទទួលព្រះពរតាមរយៈការដឹកនាំ និងការបង្រៀនរបស់លោកគ្រូ។ យើងក៏អរព្រះគុណដល់ព្រះដែលទ្រង់បានប្រទានពរលោកគ្រូស៊ុន វុទ្ធី បានទទួលការតែងតាំងពីគណៈកម្មការនាយក ដើម្បីធ្វើជាមហាវិទ្យាធិការស្តីទី។ លោកគ្រូបានបំពេញតួនាទីជានាយកកម្មវិធីសិក្សាអស់រយៈពេល២ឆ្នាំមកហើយ ហើយនឹងត្រូវបំពេញតួនាទីថ្មីនេះ។ លោកគ្រូបានសិក្សា៣ឆ្នាំហើយទទួលសញ្ញាបត្រពីសាលាព្រះគម្ពីរភ្នំពេញ និងបានធ្វើជាគ្រូគង្វាលនៅខេត្តបាត់ដំបងអស់៣ឆ្នាំ។ ក្រោយមកលោកគ្រូបានទៅបន្តការសិក្សានៅ Sydney Missionary and Bible College ប្រទេសអូស្ត្រាលី ហើយទទួលបានបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកទេវសាស្ត្រ ។ លោកគ្រូ ស៊ុន វុទ្ធី ក៏បានបំពេញការងារជាសាស្ត្រាចារ្យពេញពេល នៅសាលានេះជាង៦ឆ្នាំមកហើយ។ យើងមានក្តីរំភើបរីករាយចំពោះកិច្ចការដែលព្រះជាម្ចាស់បន្តធ្វើតាមរយៈសាលាព្រះគម្ពីរភ្នំពេញ។



## *យើងខ្ញុំសូមថ្លែងអំណរគុណចំពោះដង្វាយរបស់លោកអ្នក!*

នាម:________________________ អាសយដ្ឋាន ឬ អ៊ីមែល:________________________

លេខទូរស័ព្ទ:____________________ មកពីពួកជំនុំឬអង្គការ: ________________________

របៀបដែលលោកអ្នកអាចថ្វាយដង្វាយ:

$____________________ ឬ ថ្វាយដង្វាយរបស់លោកអ្នកដោយបញ្ចូលទៅក្នុងធនាគារកម្ពុជាសាធារណៈ គណនីលេខ # ០៩០ ០២ ១១ ០០ ១៥២១ ឬប្រគល់ជូនផ្ទាល់ដល់ផ្នែកហិរញ្ញវត្ថុរបស់សាលាព្រះគម្ពីរភ្នំពេញ។

សូមបញ្ជាក់ឲ្យបានច្បាស់ដង្វាយរបស់លោកអ្នកសម្រាប់:

- ការប្រើប្រាស់ទូទៅ ☐
- ឧបត្ថម្ភដល់និស្សិត ☐
- អភិវឌ្ឍអាគារសិក្សា ☐
- ឧបត្ថម្ភដល់បណ្ណាល័យ ☐

#អាគារ ២៥៥ ផ្លូវ២៨គ្រួសារ ភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ប្រអប់សំបុត្រ ១១៥៤
ទូរស័ព្ទលេខ ០១២ ៩៣៩ ៥០៤/ ០១៥ ៣២០ ០២១ អ៊ីមែល ppbs@ppbs.edu.kh វិបសាយ www.ppbs.edu.kh